| រឿងជោគជ័យលេចធ្លោ ស្រុកព្រៃឈរ | |
|---|---|
|  | |
| **ឈ្មោះគម្រោង** | លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **ចំណងជើងរឿង** | **ពីស្ត្រីមេផ្ទះ ទៅជាស្ត្រីសកម្មក្នុងអភិបាលកិច្ច** |
| **កាលបរិច្ឆេទនៃការកត់ត្រា** | ២០ មីនា ឆ្នាំ ២០១៥ |
| **រឿងនោះកើតឡើងនៅពេលណា** | ឆ្នាំ២០១៣ |
| **ឈ្មោះភូមិ ឬស្រុក (ទីកន្លែងដែលរឿងបានកើតឡើង)** | ភូមិអូដូនញ្ជារ ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម |
| **ឈ្មោះអ្នកនិយាយរឿងប្រាប់** | **លោកស្រី ឈុំ សុខន** សហគមន៍មូលដ្ឋាន ឃុំត្រពាំងព្រះ |
| **ចំនួនអ្នកទទួលផល (ជាក្រុម) ដែលទទួលផលពីសកម្មភាពរបស់បុគ្គលដែលផ្តល់រឿង** | ប្រជាពលរដ្ឋ ១២០គ្រួសារនៅក្នុងភូមិអូដូនញ្ជារ |
| **អាយុជាមធ្យម (បុរស ឬស្ត្រី)** | ៤៥ឆ្នាំ |
| **អ្នកសម្ភាសន៍ (តួនាទី, អង្គភាព)** | លោក ស្រី ម៉ាឡៃ បុគ្គលិកគម្រោង PROCEED អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ |
| **អ្នកកត់ត្រា (តួនាទី, អង្គភាព)** | លោក ហេង យូដា បុគ្គលិកគម្រោង PROCEED អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ |

**<u>ពិពណ៌នារឿង</u>**



លោកស្រី ឈុំ សុខន ជាស៊ីប៊ីអូស្ម័គ្រចិត្ត ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ លោកស្រី មានកូនបីនាក់ និងមានការមមាញឹកខ្លាំងក្នុងកិច្ចការផ្ទះ ។ លោកស្រីពុំធ្លាប់ស្គាល់ក្រុមប្រឹក្សាឃុំ ស្រុក និងចូលរួមក្នុងសកម្មភាពអភិវឌ្ឍរបស់ភូមិឃុំដូចស្ត្រីទូទៅក្នុងភូមិដែរ ។ លោកស្រីបញ្ជាក់ថា *“ស្ត្រីផ្សេងទៀតក៏ដូចជាខ្លួនគាត់ដែរ គឺមិនយល់ពីសិទ្ធិ និងតួនាទីរបស់ខ្លួនដែលត្រូវចូលរួមក្នុងសកម្មភាព ក្រុមប្រឹក្សាឡើយ នាំឱ្យយើងមិនបានចូលរួម និងទទួលបានព័ត៌មានពីភូមិ ឃុំ និងគ្មានទំនាក់ទំនងជាមួយតំណាងម្ចាស់ឆ្នោតទេ”*។ លោកស្ត្រី ចាប់អារម្មណ៍ចង់ចូលរួមក្នុងសកម្មភាពសង្គម និងចង់ឃើញស្ត្រីក្នុងភូមិ អាចចូលរួមកាន់តែសកម្មនៅក្នុងសកម្មភាពសង្គម និងចង់ឱ្យមនុស្សទូទៅឱ្យតម្លៃខ្ពស់ដល់ស្ត្រី នៅតាមសហគមន៍ ។ លោកស្រីធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំភូមិ និងឃុំមួយចំនួន ហើយបានដឹងពីកិច្ចការក្រុមប្រឹក្សា និងព័ត៌មានក្នុងសហគមន៍មួយចំនួនតាមរយៈចូលរួមជាសមាជិកគណៈកម្មការកៀរគរសហគមន៍ឃុំ ។ លោកស្រីបន្តចូលរួមរហូតដល់ឆ្នាំ២០១៣ លោកស្រី ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងសកម្មភាពគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ។

នៅឆ្នាំ២០១៣ ឃុំត្រពាំងព្រះបានទទួលការអនុវត្តគម្រោង “លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ” ដែលឧបត្ថមមូលនិធិពី “ទីភ្នាក់ងារអភិវឌ្ឍន៍របស់ស៊ុយអែត” តាមរយៈអង្គការផេកកម្ពុជា ។ លោកស្រីទទួលបានការបង្កើន ចំណេះដឹងបន្ថែមអំពីទស្សនៈទាននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមមាន អំពីសិទ្ធិចូលរួម តួនាទីរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់យេនឌ័រ ការពង្រឹងភាពអង់អាចដល់ស្ត្រី ជំនាញសម្របសម្រួល ការនិយាយជាសាធារណៈ និងជំនាញទំនាក់ទំនងជាដើម បានធ្វើឱ្យលោកស្រីមានភាពក្លាហាន ហ៊ានចូលរួម និងលើកបញ្ហាជូនក្រុមប្រឹក្សាឃុំ ស្រុក ខេត្ត និងអ្នកពាក់ព័ន្ធផ្សេងទៀតដោយគ្មានការភ័យខ្លាច ។

លោកស្រីចង់ឃើញការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសហគមន៍ ជាពិសេសការចូលរួមរបស់ស្ត្រីត្រូវបានគេទទួលស្គាល់ ។ លោកស្រីទទួលបានការឆ្លើយតបដោយជោគជ័យ ក្នុងការលើកបញ្ហាសាលាខ្វះគ្រូ ខ្វះសំភារៈសិក្សា

| |
|---|
| គ្មានរបងសាលា អំពើហិង្សាជូនក្រុមប្រឹក្សាឃុំឱ្យដោះស្រាយ ។ លោកស្រីចូលរួមមិនដែលខានទេនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាស្រុក ដើម្បីលើកបញ្ហា តាមដានការដោះស្រាយបញ្ហា និងស្តាប់នូវសេចក្តីសម្រេចចិត្ត ព្រមទាំងទទួលបានព័ត៌មានសំខាន់ៗពីក្រុមប្រឹក្សា និងយកទៅផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។ លោកស្រីបានផ្សព្វផ្សាយចំណេះដឹងបន្តទៅកាន់ប្រជាពលរដ្ឋប្រមាណ១២០គ្រួសារដែលភាគច្រើនជាស្ត្រី និងប្តីរបស់លោកស្រីផងដែរ ។ លោកស្រីទទួលបានការគាំទ្រពេញទំហឹងពីប្តីលោកស្រី លើកិច្ចការងារផ្ទះសំបែង និងថែទាំកូនៗ ពេលលោកស្រីទៅចូលរួមក្នុងសកម្មភាពសង្គម ។ លោកស្រីបានកៀរគរ និងលើកទឹកចិត្តស្ត្រីឱ្យទៅចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សា ជាពិសេសសកម្មភាពពិគ្រោះយោបល់ វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ និងការកសាងផែនការវិនិយោគឃុំ ។<br>ប្រជាពលរដ្ឋ និងអាជ្ញាធរភូមិ ឃុំ បានគាំទ្រ និងបានស្នើឱ្យលោកស្រី ធ្វើជាតំណាងឱ្យស្ត្រី និងប្រជាពលរដ្ឋក្នុងសហគមន៍ និងធ្វើជាគណៈកម្មការតាមដានពលកម្មកុមារប្រចាំភូមិ លោក ជា ស៊ីណា មេភូមិ អូរដូនញៀរបញ្ជាក់ថា *“លោកស្រីពិតជាមានភាពក្លាហាន ហ៊ានតស៊ូ និងសកម្មក្នុងកិច្ចការសង្គម ហើយស្ត្រីក្នុងភូមិតែងគាំទ្រ និងមានទំនុកចិត្តលើគាត់”* ។ |
| **ការអង្កេតលើចំនុចសំខាន់ៗ៖ កាយវិការ អារម្មណ៍ អត្តចរិតរបស់អ្នកទទួលសម្ភាសន៍**<br>ចំណេះដឹង ជំនឿចិត្ត ការអនុវត្តន៍ |
| <u>**ផ្នែកផ្លាស់ប្តូរ**</u> (Domain of changes)<br>អភិបាលកិច្ចល្អ |